# **<u>គោលនយោបាយឯកជនភាពរបស់ ZUELLIG PHARMA</u>**

ធ្វើបច្ចុប្បន្នភាពចុងក្រោយថ្ងៃទី៖ **13** ឧសភា **2022**

គោលនយោបាយឯកជនភាពនេះកំណត់ពីរបៀបដែលអង្គភាពផ្សេងៗនៅក្នុងក្រុមហ៊ុន **Zuellig Pharma** (បញ្ជីមិនពេញលេញនៃអង្គភាពនានារបស់យើងមាននៅផ្នែកទី **XIV** (ទាក់ទងមកយើង) នៅផ្នែកខាងក្រោម) (ដែលតទៅនេះត្រូវបានហៅជារួមថា **"Zuellig Pharma"**, "របស់យើង" ឬ "យើង") ក្នុងការដំណើរការទិន្នន័យផ្ទាល់ខ្លួន ដោយអនុលោមតាមច្បាប់ការពារទិន្នន័យដែលយើងត្រូវអនុវត្តតាម។

គោលនយោបាយឯកជនភាពនេះបង្ហាញអំពីការអនុវត្តទូទៅរបស់ក្រុមហ៊ុន ទាក់ទងនឹងការប្រមូល ការប្រើប្រាស់ ការបង្ហាញ (តទៅនេះហៅថា "ដំណើរការ") និងការការពារទិន្នន័យផ្ទាល់ខ្លួន ដែលអ្នកផ្តល់ជូនតាមរយៈគេហទំព័រ កម្មវិធី វេទិកា ទម្រង់ ផលិតផល សេវាកម្ម ឬទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យើង ឬតាមមធ្យោបាយផ្សេងទៀត (តទៅនេះហៅថា "វេទិកា") ឬនៅពេលអ្នកទំនាក់ទំនងជាមួយក្រុមហ៊ុន និង/ឬភ្នាក់ងារដែលមានការអនុញ្ញាតរបស់ក្រុមហ៊ុន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងផ្សេងៗ។ គោលនយោបាយឯកជនភាពនេះក៏ពន្យល់អំពីសិទ្ធិរបស់អ្នក និងជម្រើសដែលមានសម្រាប់អ្នកទាក់ទងនឹងការប្រើប្រាស់ សិទ្ធិចូលប្រើប្រាស់របស់អ្នក និងរបៀបធ្វើបច្ចុប្បន្នភាព និងកែតម្រូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។ ក្នុងករណីដែលវេទិការបស់យើងមានភាពខុសគ្នាពីគោលនយោបាយឯកជនភាពនេះ ឬមានបញ្ហាជាក់លាក់ផ្សេងទៀត យើងនឹងបញ្ជាក់ពីភាពខុសគ្នាទាំងនោះនៅក្នុងផ្នែកបន្ថែមជាក់លាក់មួយទៅលើគោលនយោបាយឯកជនភាពនេះ។ សេចក្តីយោងទៅពាក្យ "គោលនយោបាយឯកជនភាព" នៅក្នុងឯកសារនេះ រួមបញ្ចូលទាំងផ្នែកបន្ថែមលើគោលនយោបាយនេះផងដែរ ។

នៅក្នុងគោលនយោបាយឯកជនភាពនេះ "ទិន្នន័យផ្ទាល់ខ្លួន" ជាទូទៅសំដៅលើព័ត៌មានណាមួយដែលអាចប្រើប្រាស់បាន ដោយផ្ទាល់ ឬដោយប្រយោល (**ឧ.** ប្រើរួមជាមួយនឹងប្រភេទទិន្នន័យផ្សេងទៀតដែលយើងអាចចូលប្រើប្រាស់បាន**)** ដើម្បីកំណត់អត្តសញ្ញាណបុគ្គល (ឧទាហរណ៍ " បុគ្គលដែលទាក់ទងនឹងទិន្នន័យ " ) ច្បាប់ស្តីពីការពារទិន្នន័យក្នុងស្រុកអាចមាននិយមន័យខុសៗគ្នា ហើយប្រសិនបើវិសាលភាពដែលនិយមន័យរបស់យើងដែល បានប្រើនៅក្នុងគោលនយោបាយនេះផ្ទុយនឹងច្បាប់ និយមន័យដែលតឹងរ៉ឹងជាងនឹងត្រូវអនុវត្ត។

## I. <u>ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួន</u>

នៅក្នុងដំណើរការការងាររបស់អ្នកជាមួយក្រុមហ៊ុន ក្រុមហ៊ុនអាចប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ឬ របស់មនុស្សផ្សេងទៀត សម្រាប់គោលបំណងដូចដែលបានកំណត់នៅក្នុងគោលនយោបាយឯកជនភាពនេះ។ ការប្រើប្រាស់នេះអាចកើតឡើងនៅពេលដែលអ្នកស្ម័គ្រចិត្តផ្តល់ទិន្នន័យផ្ទាល់ខ្លួនបែបនេះដល់យើង ឬក្នុងករណីចាំបាច់ យើងទទួលបានទិន្នន័យផ្ទាល់ខ្លួនបែបនេះពីភាគីទីបី ឬពីព័ត៌មានសាធារណៈ។

នៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយក្រុមហ៊ុន ឬតាមរយៈការដែលអ្នកប្រើវេទិការបស់យើង យើងអាចប្រើប្រាស់ប្រភេទទិន្នន័យផ្ទាល់ខ្លួនខាងក្រោម រួមមានជាអាទិ៍ ៖

- ព័ត៌មានទំនាក់ទំនងផ្ទាល់ខ្លួន ដែលរួមមានឈ្មោះ អាសយដ្ឋានប្រៃសណីយ៍ អាសយដ្ឋានអ៊ីមែល ព័ត៌មានលម្អិតអំពីបណ្តាញសង្គម ឬលេខទូរស័ព្ទរបស់អ្នក។
- ទិន្នន័យផ្ទាល់ខ្លួនរសើប ដូចជាព័ត៌មានទាក់ទងនឹងសុខភាពរបស់អ្នក។
- ព័ត៌មានដែលអ្នកចុះឈ្មោះចូលប្រើគណនី រួមបញ្ចូលទាំង ID សម្រាប់ចុះឈ្មោះចូលគណនី/អាសយដ្ឋានអ៊ីមែល។ ឈ្មោះលើអេក្រង់ ពាក្យសម្ងាត់ក្នុងទម្រង់មិនអាចស្តារមកវិញបាន និង/ឬសំណួរ និងចម្លើយសុវត្ថិភាពរបស់អ្នក។
- ព័ត៌មានទំនាក់ទំនងអាជីវកម្ម ដែលរួមបញ្ចូលទាំងព័ត៌មានអំពីមុខរបរ តួនាទី និងព័ត៌មានអំពីនិយោជករបស់អ្នក។
- ព័ត៌មានទាក់ទងនឹងសញ្ជាតិ ជនជាតិ អត្តសញ្ញាណប័ណ្ណ ឬព័ត៌មានលម្អិតអំពីលិខិតឆ្លងដែនរបស់អ្នក។

- ព័ត៌មានប្រជាសាស្ត្រ និងចំណាប់អារម្មណ៍ ដែលរួមមានថ្ងៃខែឆ្នាំកំណើត អាយុ ភេទ ទីតាំងភូមិសាស្ត្រ ផលិតផល និងសេវាកម្មដែលអ្នកចូលចិត្ត ព័ត៌មានអំពីការទិញទំនិញ និងព័ត៌មានគ្រួសារ ឬរបៀបរបបរស់នៅរបស់អ្នក។
- ព័ត៌មានអំពីប្រតិបត្តិការ និងព័ត៌មានហិរញ្ញវត្ថុ ដែលរួមមានគណនីធនាគារ និងព័ត៌មានលម្អិតនៃប័ណ្ណទូទាត់ប្រាក់ ការទូទាត់ដែលអ្នកធ្វើ និងទទួលបាន និងព័ត៌មានលម្អិតផ្សេងទៀតនៃផលិតផល និងសេវាកម្មដែលអ្នកបានទិញ ឬទទួលបានពីយើង។
- ទិន្នន័យបច្ចេកទេស ដែលរួមមានអាសយដ្ឋាន IP អ៊ីនធឺណិត ប្រភេទប្រព័ន្ធប្រតិបត្តិការ ប្រភេទ និងជំនាន់ browser ព័ត៌មានអំពីឧបករណ៍របស់អ្នក និងព័ត៌មានដែលប្រមូលបានតាមរយៈការប្រើប្រាស់ឃុគឃី។
- ទិន្នន័យពីការប្រើប្រាស់ ដែលរួមបញ្ចូលព័ត៌មានអំពីរបៀបដែលអ្នកប្រើគេហទំព័រ កម្មវិធី ផលិតផល និងសេវាកម្មរបស់យើង។
- ទិន្នន័យផ្សព្វផ្សាយទីផ្សារ និងទំនាក់ទំនង ដែលរួមមានចំណូលចិត្តរបស់អ្នកសម្រាប់ការទទួលបានសម្ភារៈផ្សព្វផ្សាយទីផ្សារពីយើង និងភាគីទីបីរបស់យើង និងចំណូលចិត្តសម្រាប់ការទំនាក់ទំនងរបស់អ្នក។
- រូបថត ការថតសំឡេង និងរូបភាពរបស់អ្នកដែលត្រូវបានថតនៅលើទីតាំងរបស់យើង និង/ឬក្នុងអំឡុងពេលកម្មវិធី របស់យើង។
- ទិន្នន័យទីតាំងភូមិសាស្ត្រ។
- ការសន្ទនារបស់អ្នកជាមួយយើង (មិនថាតាមរយៈ Chat ឬការហៅទូរស័ព្ទដោយផ្ទាល់ទេ) នៅពេលអ្នកធ្វើទំនាក់ទំនងជាមួយយើងតាមរយៈបណ្តាញទំនាក់ទំនងរបស់យើង។ និង
- ព័ត៌មានផ្សេងទៀតដែលត្រូវបានអនុញ្ញាតដោយច្បាប់ជាធរមាន ឬដែលបានជូនដំណឹងដល់អ្នកនៅពេលធ្វើប្រតិបត្តិការជាមួយយើង។

លុះត្រាតែមានការហាមឃាត់ដោយច្បាប់ជាធរមាន យើងនឹងជូនដំណឹងដល់អ្នក មុននឹងប្រមូលទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក និងស្វែងរកការយល់ព្រមភ្លាមៗរបស់អ្នក ប្រសិនបើយើងត្រូវការប្រមូលទិន្នន័យផ្ទាល់ខ្លួនដែលរសើបរបស់អ្នក។

ដោយសារភាពត្រឹមត្រូវនៃទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកភាគច្រើន អាស្រ័យទៅលើព័ត៌មានដែលអ្នកផ្តល់ឱ្យយើង សូមជូនដំណឹងមកយើងឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ប្រសិនបើមានកំហុសណាមួយនៅក្នុងទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ឬប្រសិនបើមានការផ្លាស់ប្តូរទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។

ប្រសិនបើអ្នកផ្តល់ឱ្យយើងនូវទិន្នន័យផ្ទាល់ខ្លួនអំពីបុគ្គលផ្សេងទៀត សម្រាប់គោលបំណងជាក់លាក់ណាមួយ អ្នកត្រូវតំណាង និងធានាថាពួកគេបានតែងតាំងអ្នកឱ្យធ្វើសកម្មភាពជំនួសពួកគេ ហើយពួកគេបានយល់ព្រមថាអ្នកអាចៈ

- ផ្តល់ការយល់ព្រមជំនួសពួកគេចំពោះការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេ។
- ទទួលការជូនដំណឹងអំពីការការពារទិន្នន័យជំនួសពួកគេ។ និង
- ធានាថាអ្នកបានទទួលការយល់ព្រមពីពួកគេ ដើម្បីឱ្យយើងអាចរក្សាទុកទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេ ឬមានសិទ្ធិអនុញ្ញាតឱ្យយើងដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់ពួកគេ។

ជាទូទៅ ដោយសារវេទិការបស់យើងមិនផ្តោតលើអនីតិជន យើងមិនយល់ស្របក្នុងការទទួលទិន្នន័យផ្ទាល់ខ្លួនណាមួយដែលទាក់ទងនឹងអនីតិជននោះឡើយ។ ក្នុងករណីដែលសេវាកម្មជាក់លាក់ណាមួយដែលផ្តល់ដោយយើងទាមទារឱ្យមានការប្រមូល និងការដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អនីតិជន វានឹងត្រូវបានបញ្ជាក់ជាពិសេសនៅក្នុងឯកសារបន្ថែមសមស្រប ដែលភ្ជាប់ទៅនឹងគោលនយោបាយឯកជនភាពនេះ។ ក្នុងករណីបែបនេះ យើងតម្រូវឱ្យមាតាបិតា ឬអាណាព្យាបាលស្របច្បាប់របស់អនីតិជនទាំងនោះយល់ព្រមឱ្យយើងដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អនីតិជននោះ។

## II. <u>ប្រភពនៃទិន្នន័យផ្ទាល់ខ្លួន</u>

ទិន្នន័យផ្ទាល់ខ្លួនដែលយើងដំណើរការគឺទទួលបានពីប្រភពស្របច្បាប់ និងមានតម្លាភាពជាច្រើន រួមទាំងប្រភពដូចខាងក្រោមៈ

- តាមរយៈការចូលប្រើប្រាស់របស់អ្នក ឬការប្រើប្រាស់វេទិការបស់យើង។
- នៅពេលអ្នកចូលរួមក្នុងការប្រកាសស្វែងរកការផ្តល់សេវា ឬសម្រង់តម្លៃរបស់យើង នៅពេលអ្នកចុះឈ្មោះជាមួយយើងក្នុងនាមជាអ្នកផ្តល់សេវា និង/ឬបើមិនដូច្នេះទេ នៅពេលអ្នកបញ្ជូនព័ត៌មានមកយើងដើម្បីចូលរួមអនុវត្តលទ្ធកម្មរបស់យើង។
- នៅពេលអ្នកបង្កើតគណនីជាមួយយើង។
- នៅពេលអ្នករកមើល បញ្ជាទិញ ឬជាវផលិតផល និង/ឬសេវាកម្មរបស់យើង។
- នៅពេលអ្នកដាក់ពាក្យចូលរួម និង/ឬចូលរួមក្នុងការគាំទ្រអ្នកជំងឺ ការគាំទ្រផ្នែកថែទាំសុខភាព ការចូលរួមរបស់អ្នកជំងឺ និងកម្មវិធីព័ត៌មានវេជ្ជបញ្ជារបស់យើង។
- អ៊ីមែល ឬការឆ្លើយឆ្លងណាមួយដែលយើងទទួលបានពីអ្នក។
- នៅពេលដែលអ្នកទាក់ទងមកយើង និង/ឬភ្នាក់ងារដែលទទួលសិទ្ធិរបស់យើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងផ្សេងៗ និងទំនាក់ទំនងដោយផ្ទាល់ និងដោយប្រយោលណាមួយជាមួយយើង។
- នៅពេលបំពេញពាក្យសុំ ឬទម្រង់ណាមួយសម្រាប់ប្រតិបត្តិការ ឬគោលបំណងផ្សេងទៀត។
- នៅពេលអ្នកចូលរួមក្នុងព្រឹត្តិការណ៍ណាមួយ ការចាប់រង្វាន់ ឬការប្រកួតប្រជែងដែលយើងរៀបចំ ឬដោយប្រយោលតាមរយៈភាគីទីបី។
- នៅពេលបំពេញការស្ទង់មតិណាមួយដែលយើងផ្ញើទៅអ្នកសម្រាប់គោលបំណងស្រាវជ្រាវ។
- វីដេអូ ឬការថតយកនៃព្រឹត្តិការណ៍ និង/ឬសកម្មភាពនៅក្នុងបរិវេណរបស់យើង។
- ទិន្នន័យពីប្រភពដែលមានជាសាធារណៈដែលយើងប្រមូលបានដោយអនុលោមតាមច្បាប់ជាធរមាន ពោលគឺទិន្នន័យដែលអ្នកបានផ្សាយ ប្រវត្តិរូបលើប្រព័ន្ធផ្សព្វផ្សាយសង្គម បញ្ជីរាយឈ្មោះ ស្លាកសញ្ញា។
- ទិន្នន័យដែលយើងទទួលបានដោយស្របច្បាប់ពីភាគីទីបីដែលទទួលសិទ្ធិ រួមមាន ប៉ុន្តែមិនកំណត់ត្រឹមតែភ្នាក់ងាររាយការណ៍ឥណទាន ទីភ្នាក់ងារត្រួតពិនិត្យ និងអនុវត្តច្បាប់ អ្នកផ្តល់សេវាថែទាំសុខភាព និងស្ថាប័នរដ្ឋាភិបាល ឬស្ថាប័នពាក់ព័ន្ធនឹងរដ្ឋាភិបាលនានា។
- ក្រុមហ៊ុនដែលពាក់ព័ន្ធ និង/ឬក្រុមហ៊ុនដែលទាក់ទងនឹងយើង អ្នកម៉ៅការ អ្នកផ្តល់សេវាភាគីទីបី និងដៃគូអាជីវកម្ម។
- អ្នកផ្តល់សេវាផ្សព្វផ្សាយទីផ្សារ ឬដៃគូ។ និង
- បញ្ជីឈ្មោះ និងអាសយដ្ឋានសម្រាប់ផ្ញើសំបុត្រ។

## III. មូលដ្ឋានស្របច្បាប់ និងគោលបំណងនៃដំណើរការទិន្នន័យផ្ទាល់ខ្លួន

យើងត្រូវតែមានមូលដ្ឋានស្របច្បាប់ដើម្បីដំណើរការទិន្នន័យផ្ទាល់ខ្លួន។ ជាធម្មតាយើងពឹងផ្អែកលើមូលដ្ឋានស្រប ច្បាប់យ៉ាងហោចណាស់មួយក្នុងចំណោមមូលដ្ឋានស្របច្បាប់ទាំងនេះដើម្បីដំណើរការទិន្នន័យផ្ទាល់ខ្លួនៈ

- នៅពេលដែលយើងទទួលបានការយល់ព្រមពីបុគ្គលជាម្ចាស់ទិន្នន័យ សម្រាប់គោលបំណងដែលបានបង្ហាញ។
- នៅពេលដែលដំណើរការគឺជារឿងចាំបាច់ និងទាក់ទងទៅនឹងការបំពេញកិច្ចសន្យាជាមួយបុគ្គលជាម្ចាស់ទិន្នន័យ ឬដើម្បីចាត់វិធានការតាមការស្នើសុំរបស់បុគ្គលជាម្ចាស់ទិន្នន័យមុនពេលចុះកិច្ចសន្យា។
- នៅពេលដែលការដំណើរការទិន្នន័យផ្ទាល់ខ្លួនគឺជារឿងចាំបាច់សម្រាប់ការអនុលោមតាមកាតព្វកិច្ចផ្លូវច្បាប់ដែលយើងត្រូវអនុលោមតាម។
- នៅពេលដែលការដំណើរការទិន្នន័យផ្ទាល់ខ្លួន គឺជារឿងចាំបាច់ដើម្បីការពារផលប្រយោជន៍សំខាន់ៗនៃបុគ្គលជាម្ចាស់ទិន្នន័យ រួមទាំងជីវិត និងសុខភាព។
- នៅពេលដែលការដំណើរការទិន្នន័យផ្ទាល់ខ្លួនគឺជារឿងចាំបាច់ ដើម្បីឆ្លើយតបទៅនឹងភាពអាសន្នថ្នាក់ជាតិ ឬដើម្បីអនុវត្តតាមលក្ខខណ្ឌតម្រូវនៃសណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ។ ឬ
- នៅពេលដែលការដំណើរការទិន្នន័យផ្ទាល់ខ្លួនគឺជារឿងចាំបាច់ សម្រាប់គោលបំណងនៃផលប្រយោជន៍ស្របច្បាប់របស់យើង ភាគីទីបី ឬភាគីដែលទិន្នន័យត្រូវបានបង្ហាញជូន លើកលែងតែក្នុងករណីដែលផលប្រយោជន៍ទាំងនោះត្រូវបានបដិសេធដោយសិទ្ធិ

និងសេរីភាពជាមូលដ្ឋាននៃបុគ្គលជាម្ចាស់ទិន្នន័យដែលតម្រូវឱ្យមានការការពារក្រោមច្បាប់ក្នុងស្រុក។

ជាទូទៅ យើងពឹងផ្អែកលើការយល់ព្រមរបស់បុគ្គល ដើម្បីដំណើរការទិន្នន័យផ្ទាល់ខ្លួន។ លើសពីនេះ តារាងខាងក្រោមសង្ខេបអំពីគោលបំណងទូទៅមួយចំនួន ដែលយើងអាចដំណើរការទិន្នន័យផ្ទាល់ខ្លួន និងមូលដ្ឋានច្បាប់របស់យើងសម្រាប់ការធ្វើដូច្នេះ៖

| គោលបំណង | មូលដ្ឋានច្បាប់ |
|---|---|
| • ដើម្បីបង្កើត និងគ្រប់គ្រងគណនីរបស់អ្នក (ប្រសិនបើអាចធ្វើបាន)<br>• ដើម្បីឱ្យអ្នកអាចចូល ឬប្រើប្រាស់វេទិកា<br>• ដើម្បីផ្តល់ឱ្យអ្នកនូវផលិតផល និងសេវាកម្មរបស់យើង រួមទាំងដំណើរការការបញ្ជាទិញរបស់អ្នក។<br>• ដើម្បីផ្តល់ដល់អ្នកជំងឺនូវការគាំទ្រ សេវាគាំទ្រផ្នែកសុខភាព ការចូលរួមរបស់អ្នកជំងឺ និងព័ត៌មានឱសថ រួមទាំងការផ្តល់ គ្រប់គ្រង និងរៀបចំគាំទ្រអ្នកជំងឺ និងកម្មវិធីថែទាំនៅផ្ទះ។<br>• ដើម្បីផ្តល់ឱ្យអ្នកនូវការបញ្ចុះតម្លៃ ប្រាក់រង្វាន់ ការបង្វិលសង និងការផ្តល់ជូនផ្សេងទៀតសម្រាប់ការបញ្ជាទិញ និងការទិញរបស់អ្នក។<br>• ដើម្បីផ្តល់ការគាំទ្រដល់ផលិតផល និងសេវាកម្មរបស់យើង។<br>• ដើម្បីទាក់ទង និងធ្វើទំនាក់ទំនងជាមួយអ្នក រួមទាំងឆ្លើយតបនឹងសំណើរបស់អ្នក ការសាកសួរ និងដើម្បីផ្តល់ឱ្យអ្នកនូវបច្ចុប្បន្នភាពនៃស្ថានភាពបញ្ជាទិញរបស់អ្នក<br>• ដើម្បីផ្តល់ព័ត៌មាន ការជូនដំណឹង និងបច្ចុប្បន្នភាពនានា<br>• ដើម្បីបំពេញសំណើផ្សេងទៀតដែលអ្នកអាចដាក់ជូនមកយើង | ក្នុងករណីចាំបាច់ ដើម្បីអនុវត្តកិច្ចសន្យារបស់យើងជាមួយអ្នក<br><br>ក្នុងករណីដែលតម្រូវឱ្យអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់<br><br>ក្នុងករណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើង ដើម្បីធានាថាសេវាកម្មដែលស្នើសុំពីយើងត្រូវបានផ្តល់ជូនប្រកបដោយប្រសិទ្ធភាព និងសមស្រប |
| • ដើម្បីដោះស្រាយបញ្ហាសុវត្ថិភាពផលិតផល ឬការតវ៉ាលើផលិតផល និងដើម្បីទាក់ទង និងធ្វើទំនាក់ទំនងជាមួយអ្នកទាក់ទងនឹងការងារខាងលើនេះ។<br>• ដើម្បីអនុវត្តសកម្មភាពកែតម្រូវ<br>• ដើម្បីដោះស្រាយវិវាទ ឬស៊ើបអង្កេតពាក្យបណ្តឹងណាមួយដែលអ្នកបានធ្វើ ឬដែលត្រូវបានធ្វើប្រឆាំងនឹងអ្នក។ | ក្នុងករណីដែលតម្រូវឱ្យអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់<br><br>ក្នុងករណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើង ដើម្បីធានាថាពាក្យបណ្តឹងត្រូវបានស៊ើបអង្កេត និងដោះស្រាយដោយសមរម្យ |

| | |
|---|---|
| • ដើម្បីរាយការណ៍ពីព្រឹត្តិការណ៍អាក្រក់ និងសុវត្ថិភាពទាក់ទងនឹងផលិតផល ឬសេវាកម្មណាមួយ។<br>• ដើម្បីកែលម្អសេវាថែទាំអ្នកជំងឺ និងសុវត្ថិភាព ទាក់ទងនឹងការប្រើប្រាស់ផលិតផលឱសថ និងរាល់អន្តរាគមន៍ផ្នែកវេជ្ជសាស្ត្រ និងគិលានសង្គ្រោះ។<br>• ដើម្បីលើកកម្ពស់សុខភាពសាធារណៈ និង សុវត្ថិភាពទាក់ទងនឹងការប្រើប្រាស់ផលិតផលឱសថ។<br>• ដើម្បីកំណត់រកបញ្ហាទាក់ទងនឹងការប្រើប្រាស់ផលិតផលឱសថ និងពន្យល់លទ្ធផល ថ្មីៗបានទាន់ពេលវេលា។<br>• ដើម្បីលើកទឹកចិត្តដល់ការប្រើប្រាស់ផលិតផលឱសថប្រកបដោយសុវត្ថិភាព សនិទានភាព និងកាន់មានប្រសិទ្ធភាព។<br>• ដើម្បីលើកកម្ពស់ការយល់ដឹង ការអប់រំ និង ការបណ្តុះបណ្តាលផ្នែកវេជ្ជសាស្ត្រ ស្តីពីការតាមដានឥទ្ធិពលឱសថ និង ការផ្តល់ព័ត៌មានប្រកបដោយប្រសិទ្ធភាពដល់សាធារណជន | ក្នុងករណីដែលតម្រូវឱ្យអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់<br><br>ក្នុងករណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើង ដើម្បី៖<br>(a) ធានាថាការតាមដានឥទ្ធិពលឱសថត្រូវបានអនុវត្ត និង/ឬ<br>(b) លើកកម្ពស់សុខភាព និងសុវត្ថិភាពសាធារណៈ |
| • ដើម្បីរៀបចំការវិក្កយបត្រ និងធ្វើការទូទាត់<br>• ដើម្បីអនុវត្តវិធានការយកចិត្តទុកដាក់លើ ភាគីទីបីដែលយើងធ្វើប្រតិបត្តិការជាមួយ ដូចជាអ្នកលក់ និងដៃគូអាជីវកម្ម<br>• សម្រាប់មុខងារផ្ទៃក្នុងដូចជាការរាយការណ៍ និងសវនកម្ម និងការគ្រប់គ្រងហានិភ័យ<br>• ដើម្បីរក្សាប្រតិបត្តិការរបស់យើង ឬប្រព័ន្ធ គ្រប់គ្រងទំនាក់ទំនងអតិថិជន<br>• ដើម្បីរក្សា និងថែទាំកំណត់ត្រារបស់អតិថិជន ឬក្រុមហ៊ុន និងការអភិវឌ្ឍក្នុង ដំណើរការអាជីវកម្មជម្មតា។<br>• សម្រាប់ការរក្សាកំណត់ត្រាផ្ទៃក្នុងរបស់យើង។<br>• សម្រាប់ការរៀបចំ និងការអនុវត្តរាល់ឯកសារចាំបាច់ កិច្ចព្រមព្រៀង និង/ឬកិច្ចសន្យា<br>• សម្រាប់ប្រតិបត្តិការទូទៅ និងការថែទាំវេទិកា | ក្នុងករណីដែលតម្រូវឱ្យអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់<br><br>ក្នុងករណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើង ដើម្បី៖<br>(a) ធានាបាននូវប្រតិបត្តិការដោយរលូននៃអាជីវកម្មរបស់យើង និង/ឬ<br>(b) រក្សាកំណត់ត្រាត្រឹមត្រូវនៃអាជីវកម្មរបស់យើង។ |

| | |
|---|---|
| • ដើម្បីបង្កើត និងកែលម្អការផ្តល់ជូនផលិតផល និងសេវាកម្មរបស់យើង តាមរយៈការវិភាគ និងវាយតម្លៃព័ត៌មានដែលយើងមាន ដូចជាតាមរយៈការធ្វើការវិភាគទិន្នន័យ និងការស្រាវជ្រាវទីផ្សារ។<br>• ដើម្បីអភិវឌ្ឍន៍ បង្ហាញ វាស់វែង និងតាមដានការផ្សាយពាណិជ្ជកម្ម (រួមមានជាអាទិ៍ ខ្លឹមសារ ការស្ទង់មតិ និងការផ្សព្វផ្សាយវេទិកា ឬផលិតផល និងសេវាកម្មរបស់យើង ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើង ក្រុមហ៊ុនពាក់ព័ន្ធ ដៃគូអាជីវកម្ម និងភាគីទីបីផ្សេងទៀត) និងដើម្បីប្រមូលព័ត៌មានអំពីអ្នក និងអំពី របៀបដែលអ្នកធ្វើទំនាក់ទំនងជាមួយការផ្សាយពាណិជ្ជកម្មនោះ នៅពេលអ្នកប្រើវេទិកា។ | ក្នុងករណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើង ដើម្បី៖<br>(a) អភិវឌ្ឍន៍ផលិតផល ឬការផ្តល់សេវាកម្មថ្មីៗ ដើម្បីបំពេញតម្រូវការរបស់អតិថិជនរបស់យើង និង/ឬ<br>(b) កែលម្អបទពិសោធន៍អ្នកប្រើប្រាស់ នៅពេលប្រើប្រាស់ផលិតផល និងសេវាកម្មរបស់យើង រួមទាំងការប្រើប្រាស់វេទិកា។ |
| • ដើម្បីអនុវត្ត និង/ឬសម្របសម្រួលការគ្រប់គ្រងហានិភ័យ និងការក្លែងបន្លំ និងដំណើរការទូទាត់<br>• ដើម្បីទប់ស្កាត់ ស្វែងរក ឬស៊ើបអង្កេតការបំពានដែលអាចកើតមាន សកម្មភាពខុសច្បាប់ ឬមាតិកាហាមឃាត់នៅលើវេទិកា<br>• ដើម្បីអនុវត្ត និងពង្រឹងការអនុវត្តសិទ្ធិ ដែលមានចែងក្នុងគោលនយោបាយឯកជនភាពនេះ ឬកិច្ចសន្យាណាមួយ។<br>• ដើម្បីអនុលោមតាមលក្ខខណ្ឌតម្រូវផ្នែកច្បាប់ ឬបទប្បញ្ញត្តិទាក់ទងនឹងប្រតិបត្តិការពាណិជ្ជកម្មទាំងអស់ ដំណើរការអាជីវកម្ម ឬសកម្មភាពរបស់យើង ឬការផ្តល់ផលិតផល និង/ឬសេវាកម្មរបស់យើង និងដើម្បីធ្វើការបង្ហាញនៅក្រោមលក្ខខណ្ឌតម្រូវនៃច្បាប់ បទប្បញ្ញត្តិ សេចក្តីណែនាំ ដីការបស់តុលាការ គោលការណ៍ណែនាំ សារាចរ ឬក្រមនានាដែលយើង ឬសមាជិកណាមួយនៃក្រុមហ៊ុនរបស់យើងត្រូវអនុវត្តពីពេលមួយទៅពេលមួយ។<br>• សហការជាមួយនិយតករ និងស្ថាប័នអនុវត្តច្បាប់ | ក្នុងករណីដែលតម្រូវឱ្យអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់<br><br>ក្នុងករណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើង ដើម្បី៖<br>(a) បង្ការ និងស៊ើបអង្កេតវិវាទផ្លូវច្បាប់ ការបំពានដែលអាចកើតមាន សកម្មភាពខុសច្បាប់ ឬមាតិកាដែលត្រូវបានហាមឃាត់។<br>(b) អនុវត្តសិទ្ធិកិច្ចសន្យា និង/ឬ<br>(c) សហការជាមួយនិយតករ និងស្ថាប័នអនុវត្តច្បាប់ |
| • ដើម្បីជួយសម្រួលដល់ការអនុវត្តការពិនិត្យភាពត្រឹមត្រូវ ឬការផ្ទេរទ្រព្យ | ក្នុងករណីដែលតម្រូវឱ្យអនុវត្តតាមកាតព្វកិច្ចផ្លូវច្បាប់ |

| | |
|---|---|
| សម្បត្តិជាក់ស្តែង ក្នុងករណីដែលអាចមានការផ្ទេរអាជីវកម្ម ឬដែលអាចត្រូវបានស្នើឡើង ឬការផ្ទេរអាជីវកម្មជាក់ស្តែង មិនថាទាំងស្រុង ឬដោយផ្នែក ការលក់អាជីវកម្ម ការជម្រះចោល ការទិញយក ការរួមបញ្ចូលគ្នា ការបង្វិលចេញ ការបណ្តាក់ទុនរួមគ្នា ការចាត់តាំង ការរៀបចំឡើងវិញនូវអាជីវកម្ម ទ្រព្យសម្បត្តិ ឬភាគហ៊ុន ឬប្រតិបត្តិការស្រដៀងគ្នារបស់ Zuellig Pharma | ក្នុងរណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើងក្នុងការរៀបចំរចនាសម្ព័ន្ធសាជីវកម្មឡើងវិញណាមួយសម្រាប់ការរីកចម្រើន ឬការធ្វើឱ្យអាជីវកម្មរបស់យើងប្រសើរឡើង |
| • ដើម្បីផ្ញើជូនអ្នកនូវព័ត៌មាន ឬការអញ្ជើញចូលរួមកម្មវិធីសិក្ខាសាលា សន្និសីទ គំនិតផ្តួចផ្តើម និងការផ្សព្វផ្សាយ និងការពិភាក្សាដែលអ្នកអាចចាប់អារម្មណ៍<br>• ដើម្បីរៀបចំ និងគ្រប់គ្រងកម្មវិធី និងសមាជប្រកបដោយវិជ្ជាជីវៈ រួមទាំងការចូលរួមរបស់អ្នកនៅក្នុងកម្មវិធីបែបនេះ<br>• ដើម្បីផ្សព្វផ្សាយ និងផ្តល់ព័ត៌មានអំពីវេទិកា ផលិតផល និងសេវាកម្មរបស់យើង ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់យើង ក្រុមហ៊ុនពាក់ព័ន្ធ ដៃគូអាជីវកម្ម និងភាគីទីបីផ្សេងទៀត ហើយការទំនាក់ទំនងបែបនេះអាចត្រូវបានផ្តួចផ្តើមចេញពីយើង ឬតាមរយៈភាគីទីបី។<br>• ដើម្បីផ្តល់ការផ្សាយពាណិជ្ជកម្មដើម្បីផ្លាស់ប្តូរអាកប្បកិរិយាអនឡាញ (ឧ. ដើម្បីបង្ហាញអ្នកនូវការផ្សាយពាណិជ្ជកម្មតាមអ៊ីនធឺណិតសម្រាប់ផលិតផល និង/ឬសេវាកម្មដែលអ្នកអាចចាប់អារម្មណ៍ ដោយផ្អែកលើអាកប្បកិរិយាពីមុនរបស់អ្នក និងដើម្បីបង្ហាញអ្នកនូវការផ្សាយពាណិជ្ជកម្ម និងមាតិកានៅលើវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម) | ក្នុងរណីដែលវាជាផលប្រយោជន៍ស្របច្បាប់របស់យើង និងផ្អែកលើការទទួលបានការយល់ព្រមពីអ្នក ប្រសិនត្រូវបានតម្រូវនៅក្រោមច្បាប់ជាធរមាន ដើម្បីផ្តល់ឱ្យអ្នកនូវព័ត៌មានផ្សព្វផ្សាយទីផ្សារដែលអ្នកអាចចាប់អារម្មណ៍ |

## IV. <u>ផលវិបាកនៃការបដិសេធ ឬការខកខានក្នុងការផ្តល់ទិន្នន័យផ្ទាល់ខ្លួន</u>

លុះត្រាតែមានចែងផ្សេងពីនេះ ទិន្នន័យផ្ទាល់ខ្លួនដែលបានផ្តល់ឱ្យយើងគឺធ្វើឡើងដោយស្ម័គ្រចិត្តទាំងស្រុង ហើយអ្នកមិនស្ថិតនៅក្រោមកាតព្វកិច្ច ឬការបង្ខំណាមួយដើម្បីធ្វើដូច្នេះទេ។ ទោះយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈខ្លះ ប្រសិនបើអ្នកមិនផ្តល់ឱ្យយើងនូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដូចដែលបានពិពណ៌នានៅក្នុងគោលនយោបាយឯកជនភាពនេះទេ យើងនឹងមិនទទួលខុសត្រូវចំពោះផលវិបាកណាមួយដែលកើតឡើងនោះទេ។ រួមមាន៖

- ការដែលយើងមិនអាចផ្តល់ជូនអ្នកនូវផលិតផល និង/ឬសេវាកម្មដែលអ្នកបានស្នើសុំ ទាំងផលិតផល និង/ឬសេវាកម្មស្តង់ដារដូចគ្នា ឬផ្សេងគ្នាក៏ដោយ។
- ការដែលយើងមិនអាចចុះឈ្មោះអ្នកសម្រាប់កម្មវិធីអ្នកជំងឺដែលពាក់ព័ន្ធ។
- ការដែលយើងមិនអាចផ្តល់ជូនអ្នកនូវព័ត៌មានអំពីផលិតផល និង/ឬសេវាកម្មដែលអ្នកចង់បាន រួមទាំងព័ត៌មានអំពីការបញ្ចុះតម្លៃ ឬការផ្តល់ជូនពិសេស ឬផលិតផល និង/ឬសេវាកម្មថ្មីរបស់យើង។
- ការដែលយើងមិនអាចកែសម្រួលមាតិកានៃវេទិកាទៅតាមចំណូលចិត្តរបស់អ្នក ហើយបទពិសោធន៍របស់អ្នកក្នុងការប្រើប្រាស់វេទិកានេះអាចនឹងមិនរីករាយ ឬមិនមានប្រយោជន៍។
- ការដែលយើងមិនអាចបំពេញប្រតិបត្តិការពាក់ព័ន្ធជាមួយអ្នក។ និង
- ការដែលយើងមិនអាចអនុលោមតាមច្បាប់ បទប្បញ្ញត្តិជាធរមាន ការណែនាំ ដីការបស់តុលាការ ច្បាប់ក្រុមហ៊ុន គោលការណ៍ណែនាំ និង/ឬក្រមដែលយើងត្រូវអនុវត្ត។

## V. <u>ការបង្ហាញទិន្នន័យផ្ទាល់ខ្លួន</u>

ដើម្បីឱ្យយើងបំពេញគោលបំណងដែលបានរៀបរាប់ខាងលើ យើងអាចនឹងបង្ហាញទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅកាន់ភាគីខាងក្រោម រួមមានជាអាទិ៍៖

- អង្គភាពផ្សេងៗនៅក្នុងក្រុមនៃក្រុមហ៊ុនរបស់យើង (រាប់បញ្ចូលទាំងក្រុមហ៊ុនដែលបង្កើតឡើងនាពេលអនាគត) អាជ្ញាបណ្ណ ឬដៃគូអាជីវកម្ម រួមទាំង (ប្រសិនបើពាក់ព័ន្ធ) បុគ្គលិកដែលបានទទួលសិទ្ធិពីអ្នកឧបត្ថម្ភសម្រាប់កម្មវិធីអ្នកជំងឺដែលអ្នកបានចុះឈ្មោះ។
- បុគ្គលិក ភ្នាក់ងារ តំណាង ភាពជាដៃគូ អង្គភាពបណ្តាក់ទុនរួមគ្នា អ្នកម៉ៅការ អ្នកផ្តល់សេវាភាគីទីបី អ្នកម៉ៅការបន្ត ឬភាគីផ្សេងទៀត ដែលយើងអាចត្រូវបានចាត់ទុកថាចាំបាច់ ក្នុងការសម្រួលការងាររបស់អ្នកជាមួយយើង។
- អ្នកផ្គត់ផ្គង់ ក្រុមហ៊ុនផលិត និងដៃគូសម្ព័ន្ធអាជីវកម្មនៃផលិតផល និង/ឬសេវាកម្មរបស់យើង។
- អ្នកកាន់កាប់ដែលពាក់ព័ន្ធនៃសិទ្ធិទីផ្សារនៃផលិតផល និង/ឬសេវាកម្មរបស់យើង។
- ភាគីដែលយើងមានកាតព្វកិច្ចរាយការណ៍អំពីបញ្ហាសុវត្ថិភាព ឬការតវ៉ាលើផលិតផល។
- ទីប្រឹក្សាដែលមានជំនាញវិជ្ជាជីវៈរបស់យើង រួមមានជាអាទិ៍ មេធាវី គណនេយ្យករ សវនករ និងទីប្រឹក្សាហិរញ្ញវត្ថុ ឬវិជ្ជាជីវៈផ្សេងទៀតរបស់យើង ដែលត្រូវបានចាត់តាំងពាក់ព័ន្ធនឹងអាជីវកម្មរបស់យើង។
- បុគ្គល អាជ្ញាធររដ្ឋាភិបាល អាជ្ញាធរអនុវត្តច្បាប់ និយតករឧស្សាហកម្ម ឬភាគីទីបីដែលពាក់ព័ន្ធណាមួយផ្សេងទៀត ដែលយើងមានកាតព្វកិច្ចត្រូវអនុវត្ត ឬតម្រូវឱ្យធ្វើដូច្នេះ ដោយអនុលោមតាមច្បាប់ណាមួយ ឬប្រសិនបើយើងមានជំនឿដោយស្មោះត្រង់ថា ការបង្ហាញព័ត៌មានបែបនេះគឺចាំបាច់ដើម្បីថែរក្សា និង/ឬការពារសិទ្ធិរបស់យើង និងផលប្រយោជន៍ ឬពាក់ព័ន្ធនឹងការស៊ើបអង្កេតលើការក្លែងបន្លំ ការរំលោភបំពាន ការលួចចម្លង ការគេចនិងការរំលោភពន្ធ ឬសកម្មភាពខុសច្បាប់ផ្សេងទៀត។
- អ្នកទិញសក្តានុពល និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងករណីដែលអាចមានការផ្ទេរអាជីវកម្ម ឬដែលអាចត្រូវបានស្នើឡើង ឬការផ្ទេរអាជីវកម្មជាក់ស្តែង មិនថាទាំងស្រុង ឬដោយផ្នែក ការលក់អាជីវកម្ម ការជម្រះចោល ការទិញយក ការរួមបញ្ចូលគ្នា ការបង្វិលចេញ ការបណ្តាក់ទុនរួមគ្នា ការចាត់តាំង ការរៀបចំឡើងវិញនៃអាជីវកម្ម ទ្រព្យសម្បត្តិ ឬភាគហ៊ុន ឬប្រតិបត្តិការស្រដៀងគ្នារបស់ Zuellig Pharma ។ និង
- ភាគីណាមួយផ្សេងទៀត ដែលត្រូវបានស្នើសុំ ឬអនុញ្ញាតដោយអ្នក សម្រាប់គោលបំណងខាងលើ ឬគោលបំណងផ្សេងទៀតដែលទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកត្រូវបង្ហាញនៅពេលនៃការប្រមូល ឬគោលបំណងផ្សេងទៀតដែលទាក់ទងដោយផ្ទាល់ទៅនឹងគោលបំណងណាមួយខាងលើ។

ភាគីទីបីមានភារកិច្ចស្របច្បាប់ ក្នុងការដំណើរការទិន្នន័យផ្ទាល់ខ្លួនស្របតាមគោលការណ៍ដែលយើងបានបញ្ជាក់។ ភាគីទីបីក៏ទទួលខុសត្រូវតាមផ្លូវច្បាប់សម្រាប់ការធានាទិន្នន័យផ្ទាល់ខ្លួនក្នុងកម្រិតសុវត្ថិភាពសមស្របមួយ ទាក់ទងនឹងច្បាប់ការពារទិន្នន័យជាធរមាន និងស្តង់ដារឧស្សាហកម្មដែលមានការទទួលស្គាល់ទូលំទូលាយ។

## VI. ការការពារទិន្នន័យផ្ទាល់ខ្លួន

យើងធានាថារាល់កាតព្វកិច្ចរក្សាការសម្ងាត់ដែលសមស្រប និងវិធានការសុវត្ថិភាពបច្ចេកទេស និងស្ថាប័នត្រូវបានបង្កើតឡើង ដើម្បីការពារការសម្ងាត់ និងសុវត្ថិភាពនៃទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដែលត្រូវបាន ប្រមូលតាមរយៈវិធីសាស្ត្រផ្សេងៗដែលបានពិពណ៌នានៅក្នុងគោលនយោបាយឯកជនភាពនេះ ដើម្បីទប់ស្កាត់ការចូលប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការកែ ការបង្ហាញ ឬការដំណើរការដោយគ្មានការអនុញ្ញាត ឬដោយខុសច្បាប់នូវទិន្នន័យ និងព័ត៌មានទាំងនោះ និងបង្ការការបាត់បង់ ឬបំផ្លិចបំផ្លាញដោយចៃដន្យនៃព័ត៌មាន និងទិន្នន័យទាំងនោះ។

វិធានការសុវត្ថិភាពមួយចំនួនដែលយើងបានដាក់ចេញរួមមានជាអាទិ៍៖

- ការរក្សាទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងប្រព័ន្ធដែលត្រូវបានការពារដោយបណ្ដាញដែលមានសុវត្ថិភាព។
- ការដាក់ការគ្រប់គ្រងការចូលប្រើប្រាស់ដោយផ្អែកលើតួនាទី ដើម្បីកំណត់ការចូលប្រើទិន្នន័យផ្ទាល់ខ្លួន បែបនេះសម្រាប់តែបុគ្គលិកដែលមានតម្រូវការដឹងពីព័ត៌មានទាំងនេះ ក្នុងគោលបំណងអនុវត្តភារកិច្ចផ្លូវការរបស់ពួកគេ និងភាគីទីបីដែលមានការអនុញ្ញាត ដែលមានកាតព្វកិច្ចកិច្ចសន្យាក្នុងការអនុវត្តវិធានការសមស្រប ដើម្បីរក្សាទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកឱ្យមានសុវត្ថិភាព។
- ត្រួតពិនិត្យជាប្រចាំនូវប្រព័ន្ធរបស់យើងដើម្បីរកមើលភាពងាយរងគ្រោះ និងការវាយប្រហារដែលអាចកើត មាន ហើយពិនិត្យមើលជាប្រចាំនូវការប្រមូលព័ត៌មាន ការផ្ទុក និងដំណើរការអនុវត្តរបស់យើង ដើម្បីធ្វើ បច្ចុប្បន្នភាពវិធានការសុវត្ថិភាពរូបវន្ត បច្ចេកទេស និងស្ថាប័នរបស់យើង។ និង
- ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកស្នើសុំ មុនពេលពួកគេអាចចូលប្រើ ឬកែទិន្នន័យផ្ទាល់ខ្លួនដែលពួកគេមានសិទ្ធិចូលប្រើប្រាស់ស្របច្បាប់ ឬមានសិទ្ធិកែប្រែ។

ការអនុលោមតាមបទប្បញ្ញត្តិទាំងនេះនឹងត្រូវបានតម្រូវចំពោះគ្រប់ភាគីទីបីដែលមានការអនុញ្ញាត ទាំងអស់ ដែលអាចចូលប្រើទិន្នន័យផ្ទាល់ខ្លួនដូចដែលបានពិពណ៌នាខាងលើ។

## VII. សិទ្ធិរបស់អ្នក

អាស្រ័យលើច្បាប់ការពារទិន្នន័យក្នុងប្រទេសដែលអ្នករស់នៅ ទាក់ទងនឹងទិន្នន័យផ្ទាល់ខ្លួនដែលអ្នកបានដាក់ជូនយើង អ្នកអាចមានសិទ្ធិនៅពេលណាក៏បានដើម្បី៖

- ស្នើសុំចូលប្រើទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងកំណត់ត្រារបស់យើង។
- ស្នើសុំធ្វើការកែតម្រូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងកំណត់ត្រារបស់យើង ក្នុងករណីដែលព័ត៌មានមិនត្រឹមត្រូវ ខុស គ្មានបច្ចុប្បន្នភាព ឬមិនពេញលេញ នៅពេលបញ្ជាក់សុពលភាព និងផ្ទៀងផ្ទាត់ព័ត៌មានថ្មីដែលបានផ្ដល់ជូន។
- ស្នើសុំឱ្យបញ្ឈប់ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកសម្រាប់គោលបំណងផ្សព្វផ្សាយទីផ្សារ។
- ជំទាស់នឹងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ស្នើសុំដាក់កម្រិត ឬកំណត់ការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ឬស្នើសុំការចល័តទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។
- ដកការយល់ព្រមរបស់អ្នកមិនឱ្យយើងបន្តប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។ និង
- ដាក់សំណើ ឬប្ដឹងទៅអាជ្ញាធរការពារទិន្នន័យដែលពាក់ព័ន្ធអំពីការប្រមូល និងការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក។

ប្រសិនបើអ្នកមានបំណងចង់អនុវត្តសិទ្ធិណាមួយដែលបានរៀបរាប់ខាងលើ ហើយសិទ្ធិនោះត្រូវបានទទួលស្គាល់នៅក្នុងប្រទេសរបស់អ្នក សូមសរសេរមកយើង ដោយប្រើព័ត៌មានដែលមាននៅក្នុងផ្នែកទី XIV (ទាក់ទងមកយើង) នៅផ្នែកខាងក្រោម។ ទាក់ទងនឹងសំណើសុំចូលប្រើ ឬធ្វើការកែតម្រូវទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងកំណត់ត្រារបស់យើង សំណើបែបនេះត្រូវតែភ្ជាប់មកជាមួយនូវ ឯកសារដែលពាក់ព័ន្ធ តាមការតម្រូវរបស់យើង។ អាស្រ័យលើលក្ខណៈ និងភាពរសើបនៃសំណើ យើងអាចតម្រូវឱ្យអ្នកដាក់ឯកសារទាំងនេះដោយផ្ទាល់ពីពេលមួយទៅពេលមួយ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នកទៅនឹងអាសយដ្ឋានដែលមាននៅក្នុងផ្នែកទី XIV (ទាក់ទងមកយើង) ក្នុងផ្នែកខាងក្រោម។ យើងនឹងធ្វើការកែតម្រូវសមស្រប

ដោយផ្អែកលើព័ត៌មានដែលអាចបញ្ជាក់/ផ្ទៀងផ្ទាត់បាន និងធ្វើបច្ចុប្បន្នភាពតាមអ្វីដែលផ្តល់ដោយអ្នក។ សំណើរបស់អ្នកក៏អាចនឹងត្រូវបង់ថ្លៃដោយអនុលោមតាមលក្ខខណ្ឌច្បាប់ជាធរមាន។

ទាក់ទងនឹងការដកការយល់ព្រម អ្នកអាចដកទាំងស្រុង ឬដោយផ្អែកនូវការយល់ព្រមដែលអ្នកបានផ្តល់ឱ្យយើង។

អ្នកអាចស្នើសុំឱ្យយើងលុបទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ហើយយើងនឹងប្រើកិច្ចខិតខំប្រឹងប្រែងសមហេតុផលដើម្បីអនុវត្តតាមសំណើរបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ សូមចងចាំថា យើងអាចនឹងត្រូវបានតម្រូវឱ្យរក្សាទុកព័ត៌មានទាំងនោះ និងមិនលុបវាចោលក្នុងរយៈពេលដែលច្បាប់តម្រូវ ឬដើម្បីបំពេញកាតព្វកិច្ចផ្លូវច្បាប់របស់យើង។ នៅពេលដែលយើងលុបព័ត៌មានណាមួយ វានឹងត្រូវបានលុបចេញពីមូលដ្ឋានទិន្នន័យសកម្ម ប៉ុន្តែវាអាចនៅមាននៅក្នុងបណ្ណសាររបស់យើង។ យើងក៏អាចរក្សាទុកព័ត៌មានរបស់អ្នកសម្រាប់ការការពារ និងការស្វែងរកការក្លែងបន្លំ ឬគោលបំណងស្រដៀងគ្នា។

ការអនុវត្តសិទ្ធិណាមួយរបស់អ្នក ឬការដកការយល់ព្រមដូចដែលកំណត់ខាងលើ គឺនៅក្នុងករណីនីមួយៗ ផ្អែកលើការរឹតបន្តឹងផ្អែកច្បាប់ជាធរមាន លក្ខខណ្ឌកិច្ចសន្យា និងរយៈពេលសមស្រប។ វាក៏អាចផ្អែកលើថា តើវានឹងប៉ះពាល់ដល់ប្រតិបត្តិការអាជីវកម្មរបស់យើង និងសមត្ថភាពរបស់យើងក្នុងការបំពេញកាតព្វកិច្ចផ្លូវច្បាប់របស់យើងដែរ ឬទេ។

ដោយអនុលោមតាមច្បាប់ការពារទិន្នន័យដែលអនុវត្តចំពោះយើង យើងក៏អាចនឹងបដិសេធមិនធ្វើតាមសំណើរបស់អ្នកដែរ។ ប្រសិនបើយើងបដិសេធមិនអនុវត្តតាមសំណើនោះ យើងនឹងជូនដំណឹងដល់អ្នកអំពីការបដិសេធ និងហេតុផលសម្រាប់ការបដិសេធរបស់យើង។

## VIII. ការរក្សាទុកទិន្នន័យផ្ទាល់ខ្លួន

ទិន្នន័យផ្ទាល់ខ្លួនដែលអ្នកផ្តល់មកយើងនឹងត្រូវបានរក្សាទុកដរាបណាវាត្រូវបានទាមទារសម្រាប់គោលបំណងដែលវាត្រូវបានប្រមូល ឬតាមការអនុញ្ញាតដោយច្បាប់ជាធរមាន។

ទោះបីជាប្រព័ន្ធរបស់យើងត្រូវបានបង្កើតឡើងដើម្បីអនុវត្តដំណើរការលុបទិន្នន័យ ដោយយោងទៅតាមគោលការណ៍ណែនាំខាងលើក៏ដោយ ក៏យើងមិនអាចសន្យាបានទេថា ទិន្នន័យទាំងអស់នឹងត្រូវបានលុបក្នុងរយៈពេលជាក់លាក់ណាមួយនោះ ដោយសារអាចមានឧបសគ្គបច្ចេកទេស។ នៅពេលដែលយើងលែងត្រូវការប្រើទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ទិន្នន័យនោះនឹងត្រូវបានយកចេញពីប្រព័ន្ធ និងកំណត់ត្រារបស់យើង ឬទុកជាអនាមិក ដើម្បីលែងឱ្យអ្នកប្រើប្រាស់អាចកំណត់អត្តសញ្ញាណរបស់អ្នកបាន។

## IX. ការផ្ទេរទិន្នន័យផ្ទាល់ខ្លួនឆ្លងប្រទេស

ដើម្បីផ្តល់ផលិតផល និងសេវាកម្មរបស់យើង យើងអាចផ្ទេរទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅកាន់សាខា និងបុគ្គលិក ភ្នាក់ងារ និងភាគីទីបីដែលទទួលសិទ្ធិនៅក្នុងយុត្តាធិការដែលយើងធ្វើអាជីវកម្ម ឬកន្លែងដែលយើងយល់ថាសមស្រប ឬដែលយើងចង់ធ្វើ (លុះត្រាតែមានច្បាប់ជាធរមានផ្តល់កំណត់ខុសពីនេះ) សម្រាប់គោលបំណងដែលមានចែងក្នុងគោលនយោបាយឯកជនភាពនេះ។ ជាពិសេស យើងអាចផ្ទេរទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកទៅសាខានៅបរទេសរបស់យើង ដែលអាចជាកន្លែងផ្ទុកព័ត៌មានវិទ្យា និង server របស់យើង។ វាអាចមានលទ្ធភាពដែលកម្រិតនៃការការពារទិន្នន័យ នៅក្នុងយុត្តាធិការផ្សេងទៀតមិនបំពេញតាមតម្រូវការទាំងស្រុងនៃ ច្បាប់ការពារទិន្នន័យក្នុងប្រទេសដែលអ្នករស់នៅ ប៉ុន្តែការផ្ទេរទិន្នន័យទាំងអស់ត្រូវបានអនុវត្តស្របតាមលក្ខខណ្ឌតម្រូវនៃច្បាប់ជាធរមាន។

## X. តំណភ្ជាប់ទៅកាន់គេហទំព័រ ឬកម្មវិធីផ្សេងៗ

វេទិកាអាចមានតំណភ្ជាប់ទៅកាន់ និងមកពីគេហទំព័រ និងកម្មវិធីនៃបណ្តាញដៃគូរបស់យើង អ្នកផ្សាយពាណិជ្ជកម្ម អ្នកឧបត្ថម្ភកម្មវិធីអ្នកជំងឺ និង/ឬភាគីទីបីផ្សេងទៀត។ ប្រសិនបើអ្នកចុចលើតំណភ្ជាប់ទៅកាន់គេហទំព័រ ឬកម្មវិធីណាមួយក្នុងចំណោមកម្មវិធីទាំងនេះ អ្នកនឹងចាកចេញពីវេទិកា ហើយត្រូវបានបញ្ជូនបន្តទៅកាន់គេហទំព័រ ឬកម្មវិធីដែលអ្នកបានជ្រើសរើសនោះ។ ដោយសារយើងមិនអាចគ្រប់គ្រងសកម្មភាពរបស់ភាគីទីបី យើងមិនអាចទទួលយកការទទួលខុសត្រូវចំពោះការប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដោយភាគី

ទីបីនោះទេ ហើយយើងមិនអាចធានាថាពួកគេនឹងប្រកាន់ខ្ជាប់នូវការអនុវត្តឯកជនភាពទិន្នន័យដូចគ្នានឹងអ្វីដែលយើងអនុវត្តនោះទេ។ យើងលើកទឹកចិត្តឱ្យអ្នកពិនិត្យមើលគោលនយោបាយឯកជនភាពនៃគេហទំព័រ ឬកម្មវិធីទាំងនោះមុនពេលផ្តល់ទិន្នន័យផ្ទាល់ខ្លួនណាមួយ។

យើងក៏អាចអនុញ្ញាតឱ្យអ្នកចុះឈ្មោះចូល ដោយប្រើគណនីបណ្តាញសង្គមរបស់អ្នកដែរ។ ប្រសិនបើអ្នកប្រើគណនីបណ្តាញសង្គមដើម្បីចុះឈ្មោះចូលប្រើ សូមចងចាំថាអ្នកចែករំលែកព័ត៌មានប្រវត្តិរូបរបស់អ្នកជាមួយយើង ដោយផ្អែកលើការកំណត់នៃបណ្តាញសង្គមរបស់អ្នក។ យើងលើកទឹកចិត្តឱ្យអ្នកចូលទៅកាន់វេទិកាបណ្តាញសង្គមដែលពាក់ព័ន្ធ និងពិនិត្យមើលគោលនយោបាយឯកជនភាពរបស់បណ្តាញនោះ ដើម្បីយល់ពីរបៀបដែលទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកត្រូវបានចែករំលែក និងប្រើប្រាស់ក្នុងបរិបទនេះ។

## XI. ការផ្សព្វផ្សាយទីផ្សារ និងប្រមូលសិន

យើងអាចប្រើប្រាស់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដើម្បីធ្វើការផ្សព្វផ្សាយទីផ្សារផលិតផល សេវាកម្ម កម្មវិធី សិក្ខាសាលា សន្និសីទ គំនិតផ្តួចផ្តើម និងប្រមូសិន និងការពិភាក្សារបស់យើង (ឧទាហរណ៍៖ ក្រុមហ៊ុនបុត្រសម្ព័ន្ធ និង/ឬក្រុមហ៊ុនពាក់ព័ន្ធ) ដៃគូអាជីវកម្ម អ្នកឧបត្ថម្ភ និង/ឬអ្នកផ្សាយពាណិជ្ជកម្មនានា។ យើងអាចផ្តល់ព័ត៌មានផ្សព្វផ្សាយទីផ្សារបែបនេះទៅអ្នកតាមរយៈសារបង្ហោះ ការហៅទូរសព្ទ អ៊ីមែល សារជាអក្សរ (SMS) ប្រព័ន្ធផ្សព្វផ្សាយសង្គម និង/ឬបណ្តាញទំនាក់ទំនងសមស្របផ្សេងទៀត អាស្រ័យតាមអ្វីដែលអ្នកបានយល់ព្រមជាមួយយើង។ ប្រសិនបើអ្នកចង់បញ្ឈប់ការដំណើរការទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកសម្រាប់ការផ្សព្វផ្សាយទីផ្សារ និងប្រមូសិនផ្សេងៗ អ្នកអាចចុចលើតំណ **"Unsubscribe"** នៅក្នុងអ៊ីមែល ឬសារពាក់ព័ន្ធដែលអ្នកទទួលបានពីយើង។ ឬម្យ៉ាងទៀត អ្នកអាចទាក់ទងមកយើងតាមព័ត៌មាន ដែលមាននៅផ្នែកទី **XIV** (ទាក់ទងមកយើង) ក្នុងផ្នែកខាងក្រោម។ សូមចងចាំថា នៅពេលដែលយើងបានទទួលសំណើរបស់អ្នកដើម្បីឈប់ទទួលសេវា **(Unsubscribe)** វាអាចត្រូវការពេលដល់ទៅដប់បួន **(14)** ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីឱ្យយើងដំណើរការសំណើរបស់អ្នក និងធ្វើបច្ចុប្បន្នភាពនៅក្នុងប្រព័ន្ធរបស់យើង។ ដូច្នេះ អ្នកអាចនៅតែទទួលបានព័ត៌មានទំនាក់ទំនងផ្សព្វផ្សាយទីផ្សារក្នុងអំឡុងពេលនេះ។ សូមចងចាំផងដែរថា ទោះបីជាអ្នកបដិសេធមិនទទួលការទំនាក់ទំនងផ្សព្វសផ្សាយទីផ្សារក៏ដោយ អ្នកនៅតែអាចទទួលបានការទំនាក់ទំនងរដ្ឋបាលពីយើង ដូចជាការបញ្ជាទិញ ឬការបញ្ជាក់ប្រតិបត្តិការផ្សេងទៀត និងការប្រកាសសំខាន់ៗដែលមិនទាក់ទងនឹងការផ្សព្វផ្សាយទីផ្សារ។

## XII. ភាសា

ក្នុងករណីមានភាពមិនស៊ីសង្វាក់គ្នារវាងកំណែជាភាសាអង់គ្លេស និងកំណែជាភាសាក្នុងស្រុកនៃគោលនយោបាយឯកជនភាពនេះ ត្រូវយកកំណែជាភាសាអង់គ្លេសជាគោល។

## XIII. ការកែប្រែគោលនយោបាយឯកជនភាព

Zuellig Pharma រក្សាសិទ្ធិក្នុងការកែប្រែ ធ្វើបច្ចុប្បន្នភាព និង/ឬកែសម្រួលគោលនយោបាយឯកជនភាពនេះនៅពេលណាក៏បាន។ យើងនឹងចាត់វិធានការសមហេតុផលដើម្បីធានាថាការកែប្រែលើគោលនយោបាយឯកជនភាពនេះត្រូវបានជូនដំណឹងដោយការបង្ហោះការកែប្រែទាំងអស់យ៉ាងច្បាស់នៅលើវេទិកា និងកន្លែងផ្សេងទៀតដែលយើងយល់ថាសមរម្យ សម្រាប់រយៈពេលសមរម្យមួយ។ ការកែប្រែគោលនយោបាយឯកជនភាពនេះនឹងមានប្រសិទ្ធភាពភ្លាមៗ នៅពេលដែលវាត្រូវបានចេញផ្សាយនៅលើវេទិកាណាមួយ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។ យើងសូមអញ្ជើញអ្នកឱ្យពិនិត្យមើលគោលនយោបាយឯកជនភាពនេះឱ្យបានញឹកញាប់ ដើម្បីយល់ដឹងអំពីការកែប្រែដែលពាក់ព័ន្ធណាមួយ ជាពិសេសមុនពេលអ្នកផ្តល់ព័ត៌មានណាមួយដល់យើង។ ការបន្តការចូលប្រើ ឬការប្រើប្រាស់វេទិការបស់អ្នក និង/ឬការផ្តល់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកដល់យើង បន្ទាប់ពីការកែប្រែណាមួយចំពោះគោលនយោបាយឯកជនភាពនេះ បង្ហាញពីការយល់ព្រមរបស់អ្នក ចំពោះការអនុវត្តដែលបានពិពណ៌នានៅក្នុងគោលនយោបាយឯកជនភាពដែលបានកែប្រែនោះ។ ប្រសិនបើអ្នកមិនយល់ព្រមទេ អ្នកគួរតែឈប់ប្រើប្រាស់វេទិការបស់អ្នកភ្លាមៗ

ឈប់ផ្តល់ទិន្នន័យផ្ទាល់ខ្លួនរបស់អ្នកណាមួយមកយើង ហើយជូនដំណឹងជាលាយលក្ខណ៍អក្សរមកយើង តាមលក្ខណៈដែលបានពិពណ៌នានៅក្នុងផ្នែកទី VII (សិទ្ធិរបស់អ្នក) និង XIV (ទាក់ទងមកយើង)។

## XIV. ទាក់ទងមកយើង

សម្រាប់ជាឯកសារយោង
អ្នកគ្រប់គ្រង់ទិន្នន័យដែលបានរាយក្នុងតារាងខាងក្រោមជាអ្នកគ្រប់គ្រង់ទិន្នន័យចម្បងរបស់យើង នៅក្នុងប្រទេសដែលយើងកំពុងធ្វើសកម្មភាព ទោះបីជាព័ត៌មានទាំងនេះអាចផ្លាស់ប្តូរទៅតាមសេវាកម្មដែលអ្នកបានប្រើ ។
ប្រសិនបើអ្នកមានមតិកែលម្អឬសំណួរអំពីគោលនយោបាយឯកជនភាពនេះ និងវិធីដែលយើងគ្រប់គ្រងទិន្នន័យផ្ទាល់ខ្លួនរបស់អ្នក ឬអ្នកចង់អនុវត្តសិទ្ធិណាមួយរបស់អ្នកខាងលើ អ្នកនឹងត្រូវតភ្ជាប់ទៅអ្នកគ្រប់គ្រងទិន្នន័យដោយផ្ទាល់បន្ទាប់ពីទទួលបានសំណួររបស់អ្នកនៅក្នុងប្រទេសរបស់អ្នក តាមរយៈទំព័រ "ទាក់ទងយើង" នៃគេហទំព័ររបស់យើង។

| **ប្រទេស** | **អ្នកគ្រប់គ្រងទិន្នន័យ** |
|---|---|
| ប្រ៊ុយណេ | Zuellig Pharma (B) Sdn Bhd<br>ផ្ទះលេខ 5 ឡូត៍លេខ 29996 Simpang 607,<br>Kg Beribi, Jalan Gadong,<br>Bandar Seri Begawan BE1118,<br>ប្រទេសព្រុយណេដារូសាឡឹម |
| កម្ពុជា | Zuellig Pharma Ltd<br>ផ្ទះលេខ 266 ផ្លូវលំ ក្រុម 4 ភូមិរោងចក្រ<br>សង្កាត់ភ្នំពេញថ្មី<br>រាជធានីភ្នំពេញ ប្រទេសកម្ពុជា |
| ហុងកុង | Zuellig Pharma Limited<br>Suite 608, 6/F., Devon House,<br>Taikoo Place,<br>Quarry Bay ទីក្រុងហុងកុង |
| ឥណ្ឌា | Zuellig Pharma Specialty Solutions (India) Private Limited<br>35 Chandivali, Off Saki Vihar Road,<br>Andheri (E),<br>Mumbai, 400072 |
| ឥណ្ឌូណេស៊ី | PT Anugerah Pharmindo Lestari<br>Cowell Tower ជាន់ទី 12<br>Jl. Senen Raya No. 135,<br>ទីក្រុងហ្សាកាតា ១០៤១០ ប្រទេសឥណ្ឌូនេស៊ី |
| ម៉ាកាវ | Agencia Lei Va Hong Lda.<br>Rua Doca Dos Holandeses 75,<br>Ind. Chong Fong,<br>Fase A, 14/F, A/B |
| ម៉ាឡេស៊ី | Zuellig Pharma Sdn Bhd<br>No. 15 Persiaran Pasak Bumi,<br>Seksyen U8,<br>Perindustrian Bukit Jelutong,<br>40150 Shah Alam,<br>Selangor,<br>ប្រទេសម៉ាឡេស៊ី |

| | |
|---|---|
| មីយ៉ាន់ម៉ា | Zuellig Pharma Services Ltd.<br>បន្ទប់ 203 អគារ C ខុនដូ University Avenue,<br>ផ្លូវសាកលវិទ្យាល័យថ្មី<br>Bahan Township ទីក្រុងយ៉ង់ហ្គោន<br>ប្រទេសមីយ៉ាន់ម៉ា ១១២០១ |
| ហ្វីលីពីន | Zuellig Pharma Corporation<br>Km. 14 West Service Road South Superhighway cor Edison Ave.<br>Brgy. Sun Valley, Paranaque City,<br>ប្រទេសហ្វីលីពីន<br>Interpharma Solutions Philippines, Inc.<br>Km. 14 West Service Road South Superhighway cor Edison Ave.<br>Brgy. Sun Valley, Paranaque City,<br>ប្រទេសហ្វីលីពីន<br><br>Metro Drug Inc.<br>Sta. Rosa Estate, Brgy. Macabling,<br>Sta. Rosa, Laguna,<br>ប្រទេសហ្វីលីពីន |
| សិង្ហបុរី | Zuellig Pharma Pte Ltd / Zuellig Pharma Specialty Solutions Group Pte Ltd<br>15 Changi North Way<br>#01-01<br>ប្រទេសសិង្ហបុរី 498770 |
| កូរ៉េខាងត្បូង | Zuellig Pharma Korea Ltd.<br>3F, LS Yongsan Tower, 92 Hangangdaero,<br>Yongsan-gu,<br>ទីក្រុងសេអ៊ូល ប្រទេសកូរ៉េ |
| តៃវ៉ាន់ | Zuellig Pharma Inc.<br>10F, 126 Nanking E. RD. SEC 4,<br>ទីក្រុងតៃប៉ិ កោះតៃវ៉ាន់ |
| ថៃ | Zuellig Pharma Limited<br>8-9/F Ploenchit Center, 2 Sukhumvit Rd.,<br>Kwaeng Klongtoey, Khet Klongtoey,<br>បាងកក ១០១១០ |
| វៀតណាម | Zuellig Pharma Viet Nam Ltd<br>ឡូតិ៍លេខ B3, ផ្លូវឧស្សាហកម្មលេខ 4<br>តំបន់ឧស្សាហកម្ម SaiDong B តំបន់ Long Bien<br>ទីក្រុងហាណូយ ប្រទេសវៀតណាម |